# បទបង្ហាញស្តីពី
# លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០២២
# និងលើកទិសដៅការងារបន្ត
# របស់ក្រុមជំនួយការចុះមូលដ្ឋានក្រសួងអភិវឌ្ឍន៍ជនបទ

## ឆ្នាំ២០២២

# មាតិកា

I. សេចក្តីផ្តើម

II. លទ្ធផលសម្រេចបាន

III. បញ្ហាប្រឈម

IV. ទិសដៅបន្តឆ្នាំ២០២៣

VI. សេចក្តីសន្និដ្ឋាន

## I.សេចក្តីផ្តើម

ដើម្បីគាំទ្រ និងរួមចំណែកជំរុញការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្រសួងអភិវឌ្ឍន៍ជនបទបានបង្កើតក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងដើម្បីលើកកម្ពស់ កិច្ចសហការសម្របសម្រួលក្នុងការដោះស្រាយបញ្ហានានាបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវកម្មវិធីនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ របស់រដ្ឋាភិបាលកម្ពុជា។

## II. សមិទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០២២នេះ លេខាធិការដ្ឋានក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលរបាយការណ៍ពីមន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី ខេត្ត មានសំណើ ចំនួន ៤៦ ករណី ក្នុងនោះក្រសួងដោះស្រាយបានចំនួន ១៤ ករណី និងពុំទាន់បានដោះស្រាយចំនួន ៣២ ករណី។

➢ **បានដោះស្រាយ ១៤ ករណី**

- ខេត្តកំពត មាន ៩ ករណី
- ខេត្តសៀមរាប មាន ០១ ករណី
- ខេត្តត្បូងឃ្មុំ មាន ០៣ ករណី
- ខេត្តស្វាយរៀង មាន ០១ ករណី។

➢ ពុំទាន់បានដោះស្រាយ ៣២ ករណី

- ខេត្តកំពត មាន ១៣ ករណី
- ខេត្តសៀមរាប មាន ០៤ ករណី
- ខេត្តព្រះវិហារ មាន ០៥ ករណី
- ខេត្តត្បូងឃ្មុំ មាន ០១ ករណី
- ខេត្តមណ្ឌលគិរី មាន ០៧ ករណី
- ខេត្តស្វាយរៀង មាន ០២ ករណី។

## III. បញ្ហាប្រឈម

- ការធ្វើវិចារណកម្មចំណាយថវិកាថ្នាក់ជាតិ ដោយជំរុញឱ្យគ្រប់ក្រសួង ស្ថាប័ន និងអង្គភាព ចូលរួមពង្រឹងប្រសិទ្ធភាពចំណាយក្នុងបុព្វហេតុសន្សំធនធាន ដើម្បីបង្វែរថវិកាមកដោះស្រាយបញ្ហាជាអាទិភាពដែលរងផលប៉ះពាល់អវិជ្ជមានដោយសារជំងឺកូវីដ-១៩ ធ្វើឱ្យកាត់បន្ថយថវិកាវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទ
- មិនទាន់ឆ្លើយតបតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋានបានទាន់ពេលវេលា។

## IV. **ទិសដៅការងារបន្តឆ្នាំ២០២៣**

- បន្តសហការដោះស្រាយបញ្ហាប្រឈមនិងការលំបាកនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- បន្តលើកកម្ពស់ការទទួលខុសត្រូវតាមអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទតាមរយៈ ការត្រួតពិនិត្យ តាមដាន និងគាំទ្រការអនុវត្តកម្មវិធីគម្រោង និងផែនការសកម្មភាពនានានៅតាមមូលដ្ឋាន
- កៀរគរធនធានពីប្រភពនានា ដើម្បីចូលរួមដោះស្រាយជីវភាពប្រជាពលរដ្ឋក៏ដូចជាការអភិវឌ្ឍមូលដ្ឋាន
- បន្តសហការជំរុញ និងលើកកម្ពស់គណនេយ្យភាពរបស់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានឱ្យមានប្រសិទ្ធភាព។

## V. សេចក្តីសន្និដ្ឋាន

តាមរយៈការបង្កើតក្រុមជំនួយការចុះមូលដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការដោះស្រាយនូវសំណើ សំណូមពរ ប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយក៏បានចូលរួមការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ គោលនយោបាយ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នៃរដ្ឋសភាផងដែរ។

# សូមអរគុណ !